ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ : ០៣.ប្រកព

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

នៅព្រឹកថ្ងៃសុក្រ ១១កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង៨និង៣០នាទីព្រឹក នៅវិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យនិងពិភាក្សាលើ៖

**១-សេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីបរិយាប័ន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥។**

**២-សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។**

**៣-សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។**

**៤-គម្រោងវិនិយោគសាងសង់ស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យបន្ថែម៤គម្រោង អានុភាពសរុប១៤០មេហ្គាវ៉ាត់។**

**៥-បញ្ហាផ្សេងៗ។**

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចអនុម័ត៖

## ១-សេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីបរិយាប័ន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥

សេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីបរិយាប័ន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ ជាក្របខណ្ឌគោលនយោបាយជាតិ ដែលត្រូវបានរៀបចំឡើងស្របតាមចក្ខុវិស័យនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ នៃរាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងផ្អែកលើយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១៦-២០២៥ ដែលមានផែនការសកម្មភាពគ្រប់ជ្រុងជ្រោយនិងច្បាស់លាស់គាំទ្រដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាព ដើម្បីសម្រេចបាននូវប្រព័ន្ធហិរញ្ញវត្ថុមួយដែលមានស្ថិរភាព ប្រសិទ្ធភាព និងពិពិធកម្មទីផ្សារហិរញ្ញវត្ថុប្រកបដោយបរិយាប័ន្ន។

ការយកចិត្តទុកដាក់លើការពង្រីកបរិយាប័ន្នហិរញ្ញវត្ថុ គឺជានិន្នាការសកល មិនត្រឹមតែប្រទេសកម្ពុជាប៉ុណ្ណោះទេ នៅបណ្តាប្រទេសជាច្រើនក្នុងពិភពលោក និងស្ថាប័នអន្តរជាតិធំៗ ក៏បានផ្តល់អាទិភាពដល់របៀបវារៈនេះផងដែរ។ ក្នុងន័យនេះ សេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីបរិយាប័ន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ ត្រូវបានរៀបចំឡើងដោយមានគោលដៅបង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុផ្លូវការដែលមានគុណភាព កាត់បន្ថយអត្រាស្ត្រីដែលមិនទាន់ទទួលបានសេវាហិរញ្ញវត្ថុឱ្យបានពាក់កណ្តាលពី២៧% មកត្រឹម១៣% និងពង្រីកការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការពី៥៩% ទៅ៧០% ត្រឹមឆ្នាំ២០២៥ ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពគ្រួសារ គាំទ្រកំណើនសេដ្ឋកិច្ច ស្ថិរភាពចំណូល និងកាត់បន្ថយភាពក្រីក្រ។

ដើម្បីសម្រេចបានគោលដៅខាងលើ យុទ្ធសាស្ត្រជាតិស្តីពីបរិយាប័ន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ បានកំណត់នូវសកម្មភាពអាទិភាពចំនួន៦ រួមមាន៖ ១)-លើកទឹកចិត្តឱ្យមានការសន្សំនៅតាមគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ ២)-ជំរុញនវានុវត្តន៍សេវាឥណទានសម្រាប់សហគ្រាសធុនតូចនិងមធ្យម ៣)-ពង្រីកសមត្ថភាពប្រព័ន្ធទូទាត់ ៤)-ពង្រីកការផ្តល់សេវាធានារ៉ាប់រងឱ្យបានទូលំទូលាយ ៥)-ពង្រឹងសមត្ថភាពនិយ័តករវិស័យហិរញ្ញវត្ថុ និង ៦)-លើកកម្ពស់សិទ្ធិ និងបង្កើនកិច្ចការពារអតិថិជន ព្រមទាំងបង្កើនតម្លាភាពក្នុងវិស័យហិរញ្ញវត្ថុ។

ផ្អែកលើសកម្មភាពអាទិភាពទាំងនេះ ផែនការសកម្មភាពជាក់លាក់ត្រូវបានដាក់ចេញសម្រាប់វិស័យធនាគារ វិស័យមិនមែនធនាគារ ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងការពង្រឹងសមត្ថភាពនិយ័តករហិរញ្ញវត្ថុ។ ផែនការសកម្មភាពខាងលើ ត្រូវបានបែងចែកជាសកម្មភាពរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ដែលសរុបមានចំនួន១១៥សកម្មភាព។

សេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីបរិយាប័ន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ ត្រូវបានបែងចែកចេញជា៧ជំពូក រួមមាន៖ ជំពូកទី១ សេចក្តីផ្តើម ជំពូកទី២ បរិបទវិស័យហិរញ្ញវត្ថុនៅកម្ពុជា ជំពូកទី៣ ការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា ជំពូកទី៤ សកម្មភាពអាទិភាព ជំពូកទី៥ ការអនុវត្តយុទ្ធសាស្ត្របរិយាប័ន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ ជំពូកទី៦ សេចក្តីសន្និដ្ឋាន និង ជំពូកទី៧ ផែនការសកម្មភាពយុទ្ធសាស្ត្របរិយាប័ន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥។

## ២-សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់

ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ គឺជាផ្នែកមួយដ៏មានសារៈសំខាន់នៃប្រព័ន្ធច្បាប់ពិភពលោក ដែលជំរុញដំណើរការសេដ្ឋកិច្ចទីផ្សារប្រកបដោយប្រសិទ្ធភាព។ បច្ចុប្បន្ន មានប្រទេសជាច្រើននៅលើពិភពលោក ដែលក្នុងនោះប្រទេសក្នុងសហគមន៍អាស៊ានចំនួន៩ បាននិងកំពុងអនុវត្តច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។ សេចក្តីព្រាងច្បាប់នេះ នឹងជួយបំពេញបន្ថែមដល់បណ្តាច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនានាលើកិច្ចការពារអ្នកប្រើប្រាស់ រួមទាំងក្រមរដ្ឋប្បវេណីផងដែរ។

សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ មានគោលបំណងការពារផលប្រយោជន៍អ្នកប្រើប្រាស់ពីការអនុវត្តមិនសុចរិតរបស់ពាណិជ្ជករក្នុងសកម្មភាពពាណិជ្ជកម្ម ការពារសិទ្ធិនិងផលប្រយោជន៍របស់អ្នកប្រើប្រាស់ គាំទ្រទីផ្សារឱ្យមានការប្រកួតប្រជែងទាំងតម្លៃនិងគុណភាពសេវានិងទំនិញ បង្កើតបរិយាកាសនៃការធ្វើពាណិជ្ជកម្មដែលសិទ្ធិនិងផលប្រយោជន៍របស់អ្នកប្រើប្រាស់ត្រូវបានការពារ និងធ្វើឱ្យពាណិជ្ជកម្មនោះមានការប្រកួតប្រជែងដោយស្មើភាព ហើយអ្នកប្រើប្រាស់និងពាណិជ្ជករធ្វើសកម្មភាពជាមួយគ្នាប្រកបដោយទំនុកចិត្ត។

សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ត្រូវបានរៀបចំឡើងដោយមាន១១ជំពូក និង៥១មាត្រា រួមមាន៖ ជំពូកទី១ បទប្បញ្ញត្តិទូទៅ ជំពូកទី២ ស្ថាប័នមានសមត្ថកិច្ច ជំពូកទី៣ សមាគមអ្នកប្រើប្រាស់ ជំពូកទី៤ អំពើមិនសុចរិតក្នុងធុរកិច្ច ជំពូកទី៥ ការអនុវត្តមិនសុចរិត ជំពូកទី៦ ព័ត៌មានសម្រាប់អ្នកប្រើប្រាស់ ជំពូកទី៧ នីតិវិធីនៃការប្តឹងនិងការស៊ើបអង្កេត ជំពូកទី៨ នីតិវិធីនៃការចេញសេចក្តីសម្រេច ជំពូកទី៩ ការប្តឹងតវ៉ា ជំពូកទី១០ ទោសប្បញ្ញត្តិ និង ជំពូកទី១១ អវសានប្បញ្ញត្តិ។

## ៣-សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានរៀបចំឡើងដើម្បីផ្តល់វិធានជាមូលដ្ឋានដ៏សំខាន់ក្នុងការជំរុញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកក្នុងនិងក្រៅប្រទេស ប្រកបដោយទំនុកចិត្ត តាមរយៈការទទួលស្គាល់សុពលភាព អានុភាព ភាពអាចអនុវត្តបាន និងភាពអាចទទួលយកបាននៃប្រព័ន្ធអេឡិចត្រូនិក កំណត់ត្រាអេឡិចត្រូនិក និងកិច្ចសន្យាតាមប្រព័ន្ធអេឡិចត្រូនិក ព្រមទាំងមានការទទួលស្គាល់យថាភូតភាពនៃកំណត់ត្រាអេឡិចត្រូនិក និងហត្ថលេខាអេឡិចត្រូនិកដែលកំណត់ដោយស្ថាប័នរដ្ឋរបស់ព្រះរាជាណាចក្រកម្ពុជា។

សេចក្តីព្រាងច្បាប់នេះ ក៏មានគោលបំណងលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ និងការទទួលបានព័ត៌មានច្បាស់លាស់និងគ្រប់គ្រាន់អំពីទំនិញឬសេវាដាក់លក់តាមប្រព័ន្ធអេឡិចត្រូនិក ព្រមទាំងជួយរារាំងការប្រព្រឹត្តអំពើទាំងឡាយណាដែលបង្កឱ្យមានការប៉ះពាល់ដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកប្រកបដោយសុវត្ថិភាពនិងទំនុកចិត្ត។

សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបានរៀបចំឡើងដោយគោរពតាមគោលការណ៍សកលដែលត្រូវបានអនុវត្តជាអន្តរជាតិ និងបានរួមបញ្ចូលជាមួយបទពិសោធនៃការអនុវត្តរបស់បណ្តាប្រទេសនានាក្នុងសហគមន៍អាស៊ាន ពិសេសបទប្បញ្ញត្តិទាក់ទិននឹងការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក។

សេចក្តីព្រាងច្បាប់នេះ នឹងរួមចំណែកយ៉ាងសកម្មនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលនៅកម្ពុជាក្នុងការកសាងក្របខណ្ឌច្បាប់និងបទដ្ឋានគតិយុត្តនានា ដែលគាំទ្រដល់សកម្មភាពនិងប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិកនិងឌីជីថល ដែលចាំបាច់ត្រូវរៀបចំនិងធ្វើបច្ចុប្បន្នភាព ដើម្បីអាចបង្កើតសេដ្ឋកិច្ចឌីជីថលមួយរឹងមាំ ព្រមទាំងត្រៀមទទួលយកនូវការឈានមកដល់នៃបដិវត្តន៍ឧស្សាហកម្មទី៤។

សេចក្តីព្រាងច្បាប់នេះ នឹងផ្តល់លទ្ធភាពឱ្យសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជាអាចភ្ជាប់ខ្លួនទៅនឹងខ្សែសង្វាក់ផលិតកម្ម និងទីផ្សារក្នុងស្រុកនិងអន្តរជាតិ ក៏ដូចជាជំរុញឱ្យមានការច្នៃប្រឌិតនិងការបង្កើតទំនិញនិងសេវាថ្មីៗបន្ថែមទៀត។

សេចក្តីព្រាងច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានរៀបចំឡើងមាន១២ជំពូក និង៦៧មាត្រា រួមមាន៖ ជំពូកទី១ បទប្បញ្ញត្តិទូទៅ ជំពូកទី២ សុពលភាពនៃទំនាក់ទំនងអេឡិចត្រូនិក ជំពូកទី៣ ដំណើរនៃទំនាក់ទំនងអេឡិចត្រូនិក ជំពូកទី៤ កំណត់ត្រាអេឡិចត្រូនិកនិងហត្ថលេខាអេឡិចត្រូនិកដែលមានសុវត្ថិភាព ជំពូកទី៥ អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជំពូកទី៦ កិច្ចការពារអ្នកប្រើប្រាស់ ជំពូកទី៧ សកម្មភាពនិងប្រតិបត្តិការរបស់រដ្ឋតាមប្រព័ន្ធអេឡិចត្រូនិក ជំពូកទី៨ ភស្តុតាងអេឡិចត្រូនិក ជំពូកទី៩ ការទូទាត់និង/ឬការផ្ទេរប្រាក់តាមអេឡិចត្រូនិក ជំពូកទី១០ សមត្ថកិច្ច ការប្តឹងតវ៉ា និងនីតិវិធីនៃការដាក់ពិន័យ ជំពូកទី១១ ទោសប្បញ្ញត្តិ និង ជំពូកទី១២ អវសានប្បញ្ញត្តិ។

## ៤-គម្រោងវិនិយោគសាងសង់ស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ បន្ថែម៤គម្រោង អានុភាពសរុប១៤០មេហ្គាវ៉ាត់

ស្ថេរភាពនយោបាយនិងសន្តិភាពនៅកម្ពុជា បាននាំមកនូវការវិនិយោគផ្នែកសេដ្ឋកិច្ចដ៏ច្រើនលើគ្រប់វិស័យជាបន្តបន្ទាប់ រួមទាំងស្ថានភាពកាន់តែល្អនៅក្រោយការបោះឆ្នោតសកលឆ្នាំ២០១៨ បានធ្វើឱ្យសកម្មភាពវិនិយោគលើវិស័យសំណង់កើនឡើងយ៉ាងគំហុកលើសពេលមុនៗ និងបានជះឥទ្ធិពលឱ្យការប្រើប្រាស់អគ្គិសនីនៅឆ្នាំ២០១៩ និងឆ្នាំបន្តបន្ទាប់ទៀតកើនឡើងច្រើនលើសពីការគ្រោងទុក។ ក្នុងស្ថានភាពប្រែប្រួលថ្មីនេះ ដើម្បីឱ្យការផ្គត់ផ្គង់អគ្គិសនីនៅកម្ពុជាមានសុវត្ថិភាពនិងសន្តិសុខ រាជរដ្ឋាភិបាលចាំបាច់ត្រូវធ្វើការព្យាករណ៍សេចក្តីត្រូវការអគ្គិសនីឡើងវិញឱ្យបានត្រឹមត្រូវ និងត្រូវរកប្រភពអគ្គិសនីដាក់បន្ថែមជាបន្តបន្ទាប់ឲ្យបានគ្រប់គ្រាន់ទាន់តាមកំណើន ព្រមទាំងត្រូវអភិវឌ្ឍប្រព័ន្ធបណ្តាញគ្រប់ប្រភេទឱ្យមានសមត្ថភាពសមស្របសម្រាប់កំណើននៃតម្រូវការអគ្គិសនី។ តាមទិសដៅនេះ រាជរដ្ឋាភិបាលបានសម្រេចអនុម័តលើគម្រោងវិនិយោគសាងសង់ស្ថានីយផលិតអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ ចំនួន៤គម្រោងបន្ថែមទៀត ដែលមានអានុភាពសរុប១៤០មេហ្គាវ៉ាត់ ហើយត្រូវបានដាក់ពង្រាយទៅតាមទីតាំងនៃបន្ទុកប្រើប្រាស់អគ្គិសនី រួមមាន៖

- គម្រោងទី១៖ ស្ថិតនៅខេត្តពោធិ៍សាត់ មានអានុភាព៣០មេហ្គាវ៉ាត់ វិនិយោគដោយក្រុមហ៊ុន SCHNEITEC INFINITE CO., LTD. ។
- គម្រោងទី២៖ ស្ថិតនៅខេត្តបាត់ដំបង មានអានុភាព៦០មេហ្គាវ៉ាត់ វិនិយោគដោយក្រុមហ៊ុន RISEN ENERGY CO., LTD. ។

- គម្រោងទី៣៖ ស្ថិតនៅខេត្តបន្ទាយមានជ័យ មានអានុភាព៣០មេហ្គាវ៉ាត់ វិនិយោគដោយក្រុមហ៊ុន RAY POWER SUPPLY CO., LTD. ។
- គម្រោងទី៤៖ ស្ថិតនៅបាវិត ខេត្តស្វាយរៀង មានអានុភាព២០មេហ្គាវ៉ាត់ វិនិយោគដោយក្រុមហ៊ុន GREEN SUSTAINABLE VENTURES CO., LTD. ។

គម្រោងវិនិយោគទាំងបួននេះ ធ្វើឡើងក្នុងរូបភាព សាងសង់ ធ្វើជាម្ចាស់ ដំណើរការខ្លួនឯង (BOO) ក្នុងរយៈពេលសម្បទានសម្រាប់ធ្វើអាជីវកម្មសរុប២០ឆ្នាំ និងគ្រោងដាក់ឱ្យដំណើរការនៅមុនចុងឆ្នាំ២០២០។

តាមការពិនិត្យនិងវិភាគលើលក្ខណៈបច្ចេកទេស សេដ្ឋកិច្ច និងសង្គម ការវិនិយោគគម្រោងនេះមានផលប្រយោជន៍ចំពោះព្រះរាជាណាចក្រកម្ពុជា ដូចជា៖ ១)-ទទួលបានអគ្គិសនីពីប្រភពថាមពលស្អាត និងកាត់បន្ថយការប្រើប្រាស់ឥន្ធនៈដែលមានថ្លៃខ្ពស់ ២)-ផ្តល់បន្ថែមប្រភពអគ្គិសនីដោះស្រាយបង្គ្រប់កង្វះខាតផង និងជួយផ្តល់លទ្ធភាពឱ្យវារីអគ្គិសនីអាចរក្សាទឹកទុកក្នុងអាងបានច្រើនជាងមុន សម្រាប់ដំណើរការនៅពេលចាំបាច់ផង ៣)-នាំមកនូវបច្ចេកវិទ្យាថ្មី ផ្តល់ការងារជូនប្រជាពលរដ្ឋទាំងក្នុងពេលសាងសង់និងដំណើរការ ៤)-លើមូលដ្ឋាននៃច្បាប់ស្តីពីសារពើពន្ធដែលមានជាធរមាន រាជរដ្ឋាភិបាលនឹងទទួលបានចំណូលពន្ធប្រចាំឆ្នាំ ព្រមទាំងពន្ធនានាដែលអគ្គិសនីកម្ពុជានិងអ្នកចែកចាយអគ្គិសនីដទៃទៀតត្រូវបង់ជូនរដ្ឋ។

**៥-បញ្ហាផ្សេងៗ៖**

៥.១. សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានលើកឡើងអំពីមោទនភាពក្នុងនាមព្រះរាជាណាចក្រកម្ពុជា ដែលបានឡើងថ្លែងសុន្ទរកថាគន្លឹះក្នុងពិធីបើកកិច្ចប្រជុំត្រួតពិនិត្យឡើងវិញជាសកលលើកទី៧ ស្តីពី "ជំនួយសម្រាប់ពាណិជ្ជកម្ម" នៅទីស្នាក់ការអង្គការពាណិជ្ជកម្មពិភពលោក ក្រោមមូលបទ "ការគាំទ្រពិពិធកម្មនិងការលើកកម្ពស់សេដ្ឋកិច្ចសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន តាមរយៈជំនួយសម្រាប់ពាណិជ្ជកម្ម" កាលពីថ្ងៃទី៣ ដល់ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៩ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។

ក្នុងសុន្ទរកថាគន្លឹះនៅក្នុងពិធីបើកនេះ សម្តេចតេជោនាយករដ្ឋមន្ត្រី បានចែករំលែកនូវបទពិសោធរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រពាណិជ្ជកម្ម និងជោគជ័យនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ក្រោយពេលដែលកម្ពុជាបានក្លាយជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកនៅឆ្នាំ២០០៤ ព្រមទាំងតួនាទីរបស់កម្ពុជានាពេលបច្ចុប្បន្ននិងទៅអនាគត ក្នុងការទ្រទ្រង់ប្រព័ន្ធពាណិជ្ជកម្មពហុភាគី និងការបន្តរក្សាមាគ៌ាសេរីភាវូបនីយកម្មជាសកល។

៥.២. សម្តេចតេជោនាយករដ្ឋមន្ត្រី បានណែនាំដល់ក្រសួងស្ថាប័ន និងរដ្ឋបាលដែនដីពាក់ព័ន្ធត្រូវបង្កើនការយកចិត្តទុកដាក់ខ្ពស់លើការទប់ស្កាត់ការរីករាលដាលនៃជំងឺគ្រុនឈាម ដែលបានផ្ទុះឡើងក្នុងភូមិសាស្ត្រខេត្តមួយចំនួនកន្លងមក និងត្រូវចុះត្រួតពិនិត្យដល់ទីតាំងដែលបាននិងកំពុងកើតមានជំងឺប៉េស្តជ្រូកអាហ្វ្រិកនៅក្នុងភូមិសាស្ត្រខេត្តចំនួន៥ ព្រមទាំងចាត់វិធានការទប់ស្កាត់ការឆ្លងរីករាលដាល និងលុបបំបាត់ជំងឺទាំងពីរនេះប្រកបដោយប្រសិទ្ធភាពឱ្យបានទាន់ពេលវេលា។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១១ និង៣៥នាទី។

ថ្ងៃសុក្រ ១១កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩